# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាជំរុញការជួញដូរមូលបត្រ
## លើកទី៣ សម្រាប់មន្ត្រីរាជការនៃក្រសួង-ស្ថាប័នសាធារណៈ
## ស្តីពី
## "ការសន្សំមូលបត្រ"

ថ្ងៃអង្គារ ៤រោច ខែមគិសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ត្រូវនឹងថ្ងៃទី៩ ខែធ្នូ គ.ស.២០២៥ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៚៚✿៚៚

នៅថ្ងៃអង្គារ ៤រោច ខែមគិសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែធ្នូ គ.ស.២០២៥, និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) បានសហការជាមួយក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក ដោយមានការគាំទ្រពីផ្សារមូលបត្រកម្ពុជា (**ផមក**) រៀបចំសិក្ខាសាលាជំរុញការជួញដូរមូលបត្រលើកទី៣ ស្តីពី "**ការសន្សំមូលបត្រ**" ជូនដល់មន្ត្រីរាជការនៃក្រសួង-ស្ថាប័នសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** អមដោយ **ឯកឧត្តម សៀង ធីរិទ្ធ** អគ្គនាយករងនៃ **ន.ម.ក.** និងលោក **សេង ចាន់ធឿន** នាយកប្រតិបត្តិនៃក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក។ សិក្ខាសាលាជំរុញការជួញដូរមូលបត្រនេះ មានការចូលរួមផ្ទាល់ពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង-ស្ថាប័នសាធារណៈចំនួន ៥ (ប្រាំ) រួមមាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រមាណជិត ១០០ នាក់។

**ន.ម.ក.** គឺជាអាជ្ញាធរដែលគ្រប់គ្រងការវិនិយោគពាក់ព័ន្ធវិស័យមូលបត្រកម្ពុជា ដោយតែងតែយកចិត្តទុកដាក់លើផលប្រយោជន៍ស្របច្បាប់ជាចម្បងរបស់វិនិយោគិន។ ជាមួយគ្នានេះ ក្នុងគោលដៅដើម្បីជំរុញការជួញដូរមូលបត្រ ការពារផលប្រយោជន៍របស់វិនិយោគិន និងការពារការទាក់ទាញតាមការឆបោកនានា **ន.ម.ក.** តែងតែដាក់ចេញនូវយុទ្ធនាការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងជូនសាធារណជន តាមរយៈការរៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សព្វផ្សាយពីវិស័យមូលបត្រជាច្រើននៅតាមបណ្តារាជធានី-ខេត្ត។ ជាក់ស្តែង សិក្ខាសាលាជំរុញការជួញដូរមូលបត្រនេះមានគោលបំណងបង្ហាញនូវមូលដ្ឋានគ្រឹះពីវិស័យមូលបត្រ ការរៀបចំខ្លួនដើម្បីក្លាយជាវិនិយោគិនមូលបត្រ និងយុទ្ធសាស្ត្រវិនិយោគខ្លីៗជូនសិក្ខាកាមទាំងអស់ក្នុងការប្រើប្រាស់ទីផ្សារមូលបត្រជាជម្រើសថ្មីសម្រាប់ការវិនិយោគរបស់ខ្លួន ដោយផ្សារភ្ជាប់ទ្រឹស្តីទៅ

នឹងការអនុវត្តលើការជួញដូរជាក់ស្តែងក្នុងផ្សារមូលបត្រកម្ពុជា តាមរយៈកម្មវិធី CSX Trade ព្រមទាំងប្រែក្លាយសិក្ខាសាលានេះទៅជាឧបករណ៍សម្រាប់ការរៀបចំយុទ្ធសាស្ត្រវិនិយោគរបស់ខ្លួននាពេលអនាគត។

**ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** បានថ្លែងបើកកម្មវិធីថា "បើយើងទាំងអស់គ្នារួមគ្នាអភិវឌ្ឍន៍វិស័យមូលបត្រ យើងក៏រួមគ្នាទទួលបានគុណប្រយោជន៍ពីវិស័យមូលបត្រនេះផងដែរ។ **ឯកឧត្តម** បានបន្តថា វិស័យមូលបត្រគឺជាជម្រើសមួយបន្ថែមក្នុងការបង្កើនចំណូល បច្ចុប្បន្នយើងមានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រចំនួន២៥ (ម្ភៃប្រាំ) និងមានក្រុមហ៊ុនថ្មីមួយបន្ថែមទៀត គឺក្រុមហ៊ុន ពីកាសូ ស៊ីធី ហ្គាដិន (Picasso City Garden) ដែលជាក្រុមហ៊ុនក្នុងវិស័យអចលនទ្រព្យ បានកំពុងត្រៀមខ្លួនចុះបញ្ជីមូលបត្រកម្មសិទ្ធនៅផ្សារមូលបត្រកម្ពុជាផងដែរ។ ដូចនេះ យើងគួរសាកល្បងចូលរួមទិញមូលបត្រ ឬតាមដានអំពីការចុះបញ្ជីមូលបត្រមួយនេះ ក្នុងដំណាក់កាល IPO ដើម្បីមានឱកាសស្វែងយល់ពីអត្ថប្រយោជន៍ដែលទទួលបាន ក៏ដូចជាបង្កើតនូវបទពិសោធន៍វិនិយោគផ្ទាល់ដើម្បីទុកជាបទពិសោធន៍សម្រាប់ប្រើប្រាស់នាថ្ងៃអនាគត។"

**លោក សេង ចាន់ធឿន** នាយកប្រតិបត្តិនៃក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក មានមតិចំណាប់អារម្មណ៍ថា "ការសន្សំ គឺអាចមានច្រើនមធ្យោបាយបន្ថែមពីលើវិស័យផ្សេងៗទៀត ដូចជាការទទួលបានការប្រាក់ពីធនាគារ និងវិស័យអចលនទ្រព្យ ការជួញដូរមូលបត្រ ក៏វិនិយោគិនអាចធ្វើការសន្សំ និងទទួលបានចំណូលបន្ថែមពីការវិនិយោគផងដែរ។ ដូចនេះ ទីផ្សារមូលបត្របានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុញ្ញាតឱ្យសាធារណជនមានឱកាស និងលទ្ធភាពក្នុងការបង្កើនការជួញដូរ និងអាចធ្វើការផ្ទេរដើមទុនបានយ៉ាងឆាប់រហ័សដោយសុវត្ថិភាព និងប្រកបដោយប្រសិទ្ធភាព។"

សិក្ខាសាលានេះក៏មានការធ្វើបទបង្ហាញពីវាគ្មិនតំណាង **ន.ម.ក., ផមក,** និងក្រុមហ៊ុនមូលបត្ររ៉ូយ៉ាល់គ្រុប ម.ក ដែលមានជំនាញក្នុងវិស័យមូលបត្រច្រើនឆ្នាំមកហើយ។ ទន្ទឹមនឹងនេះ សិក្ខាសាលានេះក៏មានការរៀបចំជាវេទិកាកិច្ចពិភាក្សា ដែលតាមរយៈវេទិកានេះ **ឯកឧត្តម កែប សំភី** បានលើកឡើងពីចំណេះដឹងខ្លះៗថា នៅពេលវិនិយោគលើវិស័យមូលបត្រ វិនិយោគិនត្រូវបង្កើតយុទ្ធសាស្ត្រ និងពិចារណាលើការវិនិយោគជាប្រចាំ ដោយពិនិត្យមើលក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រជាលើកដំបូង។ ការវិនិយោគដំបូងជាមួយក្រុមហ៊ុនបែបនេះអាចផ្តល់សក្តានុពលក្នុងការទទួលបានប្រាក់ចំណេញរហូតដល់ ១៥០%។ សិក្ខាកាមទាំងអស់ក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាសួរដេញដោលជាមួយវាគ្មិន និងបានចូលរួមអនុវត្តការវិនិយោគជាក់ស្តែង ដោយជួញដូរមូលបត្រលើកម្មវិធី CSX Trade បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន និងគណនីជួញដូរភ្លាមៗ។

៚៚❀៚៚

សម្រាប់ព័ត៌មានបន្ថែមអាចទំនាក់ទំនង៖

- **ន.ម.ក.៖** marketsup@serc.gov.kh
- **ផ្សារមូលបត្រកម្ពុជា៖** info@csx.com.kh
- **ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក៖** brokerage@royalgroupsecurities.com.kh